ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍បាត់ដំបង

៚៚៚✵៚៚៚

សំណុំរឿងព្រហ្មទណ្ឌ
លេខៈ ៣៦៦
ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២១

**សាលដីកា**
លេខៈ ២០ (ខ)
ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០២២

**តាងនាមប្រជារាស្ត្រខ្មែរ**

**សាលាឧទ្ធរណ៍បាត់ដំបង**

បង្កើតឡើងតាមច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស០១៥/០៧១៤/រកម/ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ និងព្រះរាជក្រឹត្យលេខ នស/រតក/០២២០/១៩៨ ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២០ ស្តីពីការដាក់ឱ្យដំណើរការសាលាឧទ្ធរណ៍តំបន់ បានបើកសវនាការជាសាធារណៈ នៅសាលសវនាការនៃសាលាឧទ្ធរណ៍បាត់ដំបង នាថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២១ ដោយមានសមាសភាពដូចតទៅៈ

**ក្រុមប្រឹក្សាជំនុំជម្រះ**

ឯកឧត្តម [redacted] ប្រធានក្រុមប្រឹក្សា

លោក [redacted] ចៅក្រមប្រឹក្សា

លោក [redacted] ចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញា

**ក្រឡាបញ្ជីសវនាការ**

លោក [redacted]

ដើម្បីពិភាក្សាដេញដោលលើសំណុំរឿងព្រហ្មទណ្ឌលេខ ៣៦៦ ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២១ ដែលមានៈ

-ជនជាប់ចោទឈ្មោះ [redacted] **បារាំង** ភេទប្រុស អាយុ២៧ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ សាសនា ព្រះពុទ្ធ មានទីកន្លែងកំណើតនៅ ភូមិព្រៃកស្រមោច ឃុំកំពង់ឃ្លាំង ស្រុកសូទ្រនិគម ខេត្តសៀមរាប មានទីលំនៅមុនពេលឃុំខ្លួននៅ [redacted] ស្រុកសូទ្រនិគម ខេត្តសៀមរាប មុខរបរ ជាងដែក កម្រិតវប្បធម៌ថ្នាក់ទី០៦ ប្រពន្ធឈ្មោះ [redacted] (រស់) គ្មានកូន ឪពុកឈ្មោះ [redacted] (រស់) ម្តាយឈ្មោះ [redacted] (រស់) ទោសពីមុន គ្មាន ។ (ក្នុងឃុំ) (**ប្តឹងឧទ្ធរណ៍**)

ដីកាបង្គាប់ឱ្យចាប់ខ្លួនលេខ ០៤ ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៦ របស់ប្រធានក្រុមប្រឹក្សាជំនុំជម្រះសាលាដំបូងខេត្តសៀមរាប ។

ដីកាបង្គាប់ឱ្យឃុំខ្លួនពិរុទ្ធជនលេខ ១៧៦/២០២១ ចុះថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០២១ របស់ព្រះរាជអាជ្ញាអមសាលាដំបូងខេត្តសៀមរាប ។

<u>ជាប់ចោទពីបទៈ</u> រំលោភសេពសន្ថវៈដោយមានស្ថានទម្ងន់ទោសទាក់ទងទៅនឹងជនរងគ្រោះ ប្រព្រឹត្តនៅភូមិព្រៃកស្រមោច ឃុំកំពង់ឃ្លាំង ស្រុកសូទ្រនិគម ខេត្តសៀមរាប កាលពីថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៥ បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៤១ ចំណុចទី១ នៃក្រមព្រហ្មទណ្ឌ ។

មានលោក [redacted] វីរៈ ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សុជាតិ ភេទប្រុស សញ្ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្នភូមិព្រៃកស្រមោច ឃុំកំពង់ឃ្លាំង ស្រុកសូទ្រនិគម ខេត្តសៀមរាប ។

## <u>ឯរឿងហេតុមានដូចតទៅ</u>

កាលពីថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៥ ស្ថិតនៅភូមិព្រៃកស្រមោច ឃុំកំពង់ឃ្លាំង ស្រុកសូទ្រនិគម ខេត្តសៀមរាប ឈ្មោះ [redacted] ស្រីអូន ភេទស្រី អាយុ០៩ឆ្នាំ បានដើរទៅបត់ជើងធំជាមួយឈ្មោះ យ៉ុង និង ឈ្មោះ ហុង ក៏បានជួបជាមួយឈ្មោះ [redacted] បារាំង ភេទប្រុស អាយុ២១ឆ្នាំ កំពុងដើរបាញ់សត្វ ហើយឈ្មោះ [redacted] បារាំង បានបបួលឈ្មោះ ជាតិ ស្រីអូន ទៅក្បែរស្រះចិញ្ចឹមត្រី ។ ពេលទៅដល់ឈ្មោះ [redacted] បារាំង បានចាប់ស្រាតខោ និងឱ្យឈ្មោះ [redacted] ស្រីអូន ដេកទៅលើដី និងបានយក [redacted] ស្រីអូន រួចក៏ឱ្យឈ្មោះ [redacted] ស្រីអូន [redacted] ខ្លួនទៀត ។ លុះក្រោយមកប្រព្រឹត្តរួចឈ្មោះ [redacted] បារាំង បានឱ្យប្រាក់ទៅឈ្មោះ [redacted] ស្រីអូន ចំនួនមួយពាន់រៀល ។

**-បានឃើញ សាលក្រមលេខៈ ៦០ "ជ" ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៥ របស់សាលាដំបូងខេត្តសៀមរាប ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅៈ**

១-ផ្តន្ទាទោសជនជាប់ចោទៈ

-ឈ្មោះ [redacted] បារាំង ភេទប្រុស អាយុ២១ឆ្នាំ (សាវតារជាតិដូចខាងលើ) ដាក់ពន្ធនាគារកំណត់ ៥ (ប្រាំ)ឆ្នាំ គិតពីថ្ងៃចាប់ខ្លួនបាន ។

ពីបទ រំលោភសេពសន្ថវៈដោយមានស្ថានទម្ងន់ទោសទាក់ទងទៅនឹងជនរងគ្រោះ ប្រព្រឹត្តនៅភូមិព្រៃកស្រមោច ឃុំកំពង់ឃ្លាំង ស្រុកសូទ្រនិគម ខេត្តសៀមរាប កាលពីថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៥ បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៤១ ចំនុចទី១ នៃក្រមព្រហ្មទណ្ឌ ។

២-ចេញដីកាបង្គាប់ឱ្យចាប់ខ្លួនលើជនជាប់ចោទឈ្មោះ [redacted] បារាំង (ដែលមានសាវតារជាតិដូចខាងលើ) តាមបញ្ញត្តិមាត្រា ៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

៣-សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈ នៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៥ កំបាំងមុខជនជាប់ចោទ និងដើមបណ្ដឹងរដ្ឋប្បវេណី ។ ទុកសិទ្ធិប្តឹងទាស់ និងឧទ្ធរណ៍តាមកំណត់ច្បាប់។

**-បានឃើញ**: ពាក្យបណ្តឹងទាស់ថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០២១ របស់ជនជាប់ចោទឈ្មោះ [redacted] **បារាំង** ប្តឹងទាស់សាលក្រមលេខៈ ៦០ "ជ" ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៥ របស់សាលាដំបូងខេត្តសៀមរាប ត្រង់ចំណុច **សេចក្តីសម្រេចទាំងមូល** ។

**-បានឃើញ សាលក្រមលេខៈ ១៤ "ង.១"/៥១១ ចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០២១ របស់សាលាដំបូងខេត្តសៀមរាប ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ÷**

១-ទទួលពាក្យបណ្ដឹងទាស់ចុះថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០២១ របស់ជនជាប់ចោទឈ្មោះ [redacted] **បារាំង** (អត្តសញ្ញាណដូចខាងលើ) ។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ **៦០ "ជ"** ចុះថ្ងៃទី**៣០** ខែ**វិច្ឆិកា** ឆ្នាំ**២០១៥** ទុកជាបានការដោយសម្រេចផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] **បារាំង** ភេទប្រុស អាយុ២៧ឆ្នាំ (អត្តសញ្ញាណដូចខាងលើ) ដាក់ពន្ធនាគារកំណត់រយៈពេល **០៥ ឆ្នាំ** ។

ពីបទ **រំលោភសេពសន្ថវៈដោយមានស្ថានទម្ងន់ទោសទាក់ទងទៅនឹងជនរងគ្រោះ** ប្រព្រឹត្តនៅភូមិព្រៃកស្រមោច ឃុំកំពង់ឃ្លាំង ស្រុកសូទ្រនិគម ខេត្តសៀមរាប កាលពីថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៥ បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៤១ ចំណុចទី១ នៃក្រមព្រហ្មទណ្ឌ ។

សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈ នៅថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០២១ ចំពោះមុខជនជាប់ចោទ និងជនរងគ្រោះ ។

ទុកសិទ្ធិឱ្យប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

**-បានឃើញ**: ពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២១ របស់ជនជាប់ចោទឈ្មោះ [redacted] **បារាំង** ប្តឹងឧទ្ធរណ៍នឹងសាលក្រមលេខៈ ១៤ "ង.១"/៥១១ ចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០២១ របស់សាលាដំបូងខេត្តសៀមរាប ត្រង់ចំណុច **ទី២ នៃសេចក្តីសម្រេចបញ្ចប់** ។

**-បានឃើញ**: របាយការណ៍រឿងរបស់ចៅក្រមរបាយការណ៍ ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២១ ។

**-បានឃើញ**: សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០២១ ។

**<u>នាពេលសវនាការ</u>**

-ជនជាប់ចោទឈ្មោះ [redacted] **បារាំង** (វត្តមាន)

-លោក [redacted]រ៉ៈ ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ (វត្តមាន)

-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted]សុជាតិ (អវត្តមាន)

-ប្រធានក្រុមប្រឹក្សាជំនុំជម្រះសង្ខេបរបាយការណ៍រឿង

-ជនជាប់ចោទឈ្មោះ [redacted] **បារាំង** បានឆ្លើយថា ខ្លួនមិនបានប្រព្រឹត្តដូចគេចោទប្រកាន់ខ្លួនទេ ។ ចម្លើយដែលឈ្មោះ [redacted] ស្រីអូន ឆ្លើយ អត់ពិតទេ ។ ខ្លួននៅតែរក្សាចម្លើយដូចនៅសាលាដំបូងដដែល ។ ខ្លួនអត់បានធ្វើទេ ។ ខ្លួនសំណូមពរឱ្យតុលាការលើកលែងការចោទប្រកាន់ដល់ខ្លួនផង ។

**-តំណាងមហាអយ្យការបានធ្វើសេចក្ដីសន្និដ្ឋានថា** បន្ទាប់ពីធ្វើការពិភាក្សាដេញដោល និងពិនិត្យសំណុំរឿងរួចមក ឃើញថា នៅក្នុងរឿងនេះ ពាក់ព័ន្ធនឹងការរំលោភសេពសន្ថវៈ ហើយជនជាប់ចោទឈ្មោះ [redacted] បារាំង បានប្ដឹងឧទ្ធរណ៍មិនសុខចិត្តនឹងសាលក្រមរបស់សាលាដំបូង ដែលបានសម្រេចផ្ដន្ទាទោសលើជនជាប់ចោទចំនួន ០៥(ប្រាំ)ឆ្នាំ ពីបទ រំលោភសេពសន្ថវៈមានស្ថានទម្ងន់ទោសទាក់ទងនឹងជនរងគ្រោះ ។ តំណាងមហាអយ្យការ យល់ឃើញថា ពិតជាមានអង្គហេតុរំលោភពិតប្រាកដមែន ដោយសារមានចម្លើយជនរងគ្រោះ និងសាក្សីក្មេងៗហ្នឹង ដែលបានបញ្ជាក់ថា ជនជាប់ចោទពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់មែន ។ ដូច្នេះតំណាងមហាអយ្យការ ស្នើសុំឱ្យក្រុមប្រឹក្សាជំនុំជម្រះ តម្កល់សាលក្រមរបស់សាលាដំបូងខេត្តសៀមរាប ទុកជាបានការដដែល ។

**-មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទបានធ្វើសេចក្ដីសន្និដ្ឋានថា** នៅក្នុងរឿងនេះ ឃើញថា តាំងពីដំណាក់កាលដំបូង កូនក្ដីខ្លួនបានបដិសេធថា មិនបានប្រព្រឹត្តដូចការចោទប្រកាន់នោះទេ ។ ពាក់ព័ន្ធនឹងរឿងរ៉ាវដែលកើតឡើង សុទ្ធតែជាវិមតិសង្ស័យតែប៉ុណ្ណោះ ។ ចំពោះទំនាក់ទំនងគ្រួសារគាត់មានការឈ្លោះអ៊ីចឹងរឿងរ៉ាវដែលកើតឡើងនេះ គឺមានការសង្ស័យ អាចនាំឱ្យមានការចោទប្រកាន់ ។ ចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ចម្លើយសាក្សីផ្សេងសុទ្ធតែជាបងប្អូនរបស់ជនរងគ្រោះ សុទ្ធតែស្ថិតក្នុងរង្វង់ញាតិរបស់ជនរងគ្រោះ ចំណុចនេះខ្លួនសូមបដិសេធ ។ ពាក់ព័ន្ធនឹងឯកសារកោសលវិច័យ ដែលជាបន្ទុកនៃភស្តុតាង ក៏ពុំមានផងដែរ អ៊ីចឹងគ្រាន់តែជាការអះអាងរបស់ដើមបណ្ដឹងរដ្ឋប្បវេណីថា បានយកកូនទៅមន្ទីរពេទ្យហើយ មានការដាក់សន្ទះព្រហ្មចារី នោះ ។ ដើមបណ្ដឹងរដ្ឋប្បវេណី បានសម្រុះសម្រួលគ្នាដោយមានការសំណង ដោយសំណងនេះមិនមែនមានន័យថា កូនក្ដីខ្លួនបានប្រព្រឹត្តនោះទេ គឺក្នុងគោលបំណងថា មិនចង់វែងឆ្ងាយជាមួយគ្នា ដើម្បីឱ្យរឿងហ្នឹងចប់ ហើយដើមបណ្ដឹងរដ្ឋប្បវេណី ក៏បានដកពាក្យបណ្ដឹងផងដែរ ។ ដូច្នេះ ខ្លួនស្នើសុំឱ្យក្រុមប្រឹក្សាជំនុំជម្រះ ដោយសម្រេចឱ្យកូនក្ដីខ្លួនបានរួចផុតពីការចោទប្រកាន់ និងដោះលែងកូនក្ដីខ្លួន ដោយក្ដីអនុគ្រោះ ។

-ក្រោយពីបានស្ដាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្ដាប់អំណានចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណី

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្ដាប់សំណូមពររបស់ជនជាប់ចោទ

-ក្រោយពីបានពិនិត្យឯកសារក្នុងសំណុំរឿងហើយ

-ក្រោយពីបានពិភាក្សា និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

# សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍បាត់ដំបង

## យល់ឃើញថា

១.ពាក្យបណ្ដឹងឧទ្ធរណ៍ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២១ របស់ឈ្មោះ [redacted] បារាំង ធ្វើឡើងតាមកំណត់ច្បាប់ សាលាឧទ្ធរណ៍បាត់ដំបង ទទួលជំនុំជម្រះបានយោងតាមបញ្ញត្តិមាត្រា ៣៨២ថ្មី នៃច្បាប់ស្តីពីវិសោធនកម្ម មាត្រា ២៤៧ មាត្រា ៣៦៨ មាត្រា ៣៧២ និងមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

២.ជនជាប់ចោទឈ្មោះ[redacted] បារាំង បានឆ្លើយបដិសេធថា ខ្លួនមិនបានប្រព្រឹត្តទេ ។ នៅថ្ងៃកើតហេតុខ្លួននៅផ្ទះមិនបានជួបជាមួយឈ្មោះ[redacted]ស្រីអូន នោះទេ ។ ឪពុករបស់ឈ្មោះ[redacted]ស្រីអូន ត្រូវជាឪពុកមាខ្លួន ប៉ុន្តែខ្លួនមិនដែលនិយាយរកគ្រួសារឈ្មោះ[redacted]ស្រីអូន ទេ ព្រោះគ្រួសារខ្លួនធ្លាប់មានទំនាស់ជាមួយគ្រួសារឈ្មោះ [redacted] ស្រីអូន ។ ខ្លួនមិនបានយកប្រដាប់ភេទខ្លួនឱ្យឈ្មោះ[redacted] ស្រីអូន [redacted]ហើយក៏មិនបានបញ្ចូលប្រដាប់ភេទខ្លួនទៅក្នុងប្រដាប់ភេទឈ្មោះ ស្រីអូន ទេ ហើយក៏មិនបានឱ្យលុយទៅឈ្មោះ[redacted] ស្រីអូន មួយពាន់រៀលនោះទេ ។

៣.ជនជាប់ចោទឈ្មោះ [redacted]បារាំង បានបដិសេធថា ខ្លួនពុំបានប្រព្រឹត្តដូចការចោទប្រកាន់នោះទេ ប៉ុន្តែតាមចម្លើយរបស់ជនរងគ្រោះឈ្មោះ[redacted] ស្រីអូន បានបញ្ជាក់ថា នៅថ្ងៃកើតហេតុខ្លួនបានទៅបន្ទោរបង់នៅខាងលិចផ្ទះជាមួយឈ្មោះ យ៉ុង និងឈ្មោះ ហុង ក៏បានឃើញឈ្មោះ បារាំង កំពុងដើរបាញ់សត្វម្នាក់ឯង ហើយគេបានបបួលខ្លួនទៅក្បែរស្រះចិញ្ចឹមត្រី ចំណែកឈ្មោះ យ៉ុង និងឈ្មោះ ហុង មិនបានទៅទេ ។ ពេលទៅដល់ឈ្មោះ បារាំង បានចាប់សម្រាតខោខ្លួន ហើយឱ្យដេកលើដី បន្ទាប់មកវាឡើងជិះពីលើ រួចបញ្ចេញ [redacted] ។ បន្ទាប់មកវាឱ្យខ្លួន [redacted]ឈ្មោះ [redacted]ក៏បានហុចប្រាក់ឱ្យខ្លួនចំនួនមួយពាន់រៀល ហើយដើរទៅបាញ់សត្វបាត់ ខ្លួនបានយកប្រាក់នោះមកហែកចោល ។ ហើយតាមចម្លើយបំភ្លឺរបស់សាក្សីឈ្មោះ[redacted]ហាងគុណ និងឈ្មោះ[redacted]ចន្ធូ បានបញ្ជាក់ថា បានឃើញឈ្មោះ[redacted]បារាំង ចាប់ស្រាតខោរបស់ឈ្មោះ ស្រីអូន រួចដេ[redacted]។

៤.តាមចម្លើយរបស់ជនរងគ្រោះ និងតាមការបំភ្លឺរបស់សាក្សីបានបញ្ជាក់ឱ្យឃើញថា ជនជាប់ចោទឈ្មោះ[redacted]បារាំង ពិតជាបានរំលោភសេពសន្ថវៈលើជនរងគ្រោះឈ្មោះ [redacted]ស្រីអូន ប្រាកដមែន ។

៥.រឿងក្ដីនេះ សាលាដំបូងខេត្តសៀមរាប បានធ្វើការអង្កេត និងលើកយកភស្តុតាងមកសំអាងជូនតុលាការសព្វគ្រប់ហើយ សាលាឧទ្ធរណ៍បាត់ដំបងឯកភាពលើសំអាងហេតុនេះ ដូច្នេះសាលាឧទ្ធរណ៍បាត់ដំបងពុំចាំបាច់លើកយកសំអាងហេតុដដែលនេះ មកបញ្ជាក់ជាថ្មីទៀតទេ ។

៦.តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍បាត់ដំបង បានធ្វើសេចក្ដីសន្និដ្ឋានសុំឱ្យក្រុមប្រឹក្សាជំនុំជម្រះសាលាឧទ្ធរណ៍បាត់ដំបងសម្រេចតម្កល់សាលក្រមព្រហ្មទណ្ឌលេខ ១៤ “ង.១”/៥១១ ចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០២១ របស់សាលាដំបូងខេត្តសៀមរាប ទុកជាបានការដដែល ។

៧.សាលក្រមព្រហ្មទណ្ឌលេខ ១៤ "ង.១"/៥១១ ចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០២១ របស់សាលាដំបូងខេត្តសៀមរាប ដែលសម្រេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវហើយ គប្បីតម្កល់ទុកជាបានការដដែល ។

## ហេតុដូច្នេះវិនិច្ឆ័យសេចក្តី

១. ទទួលពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២១ របស់ឈ្មោះ [redacted]ហាំង ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២. តម្កល់ សាលក្រមព្រហ្មទណ្ឌលេខ ១៤ "ង.១"/៥១១ ចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០២១ របស់សាលាដំបូងខេត្តសៀមរាប ទុកជាបានការដដែល ។

-សាលដីកានេះ ជំនុំជម្រះជាសាធារណៈ នាថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២១ ចំពោះមុខជនជាប់ចោទ និងប្រកាសជាសាធារណៈ នាថ្ងៃទី១៤ ខែមករា ឆ្នាំ២០២២ កំបាំងមុខជនជាប់ចោទ តែចាត់ទុកជាចំពោះមុខ ។ បើកផ្លូវប្តឹងសាទុក្ខតាមកំណត់ច្បាប់ ។

| **ក្រឡាបញ្ជី** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ** |
|---|---|---|
| ហត្ថលេខា [redacted] | ហត្ថលេខា [redacted], [redacted] | ហត្ថលេខា [redacted] |

---

**បានឃើញ**

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃសុក្រ ១២កើត ខែបុស្ស ឆ្នាំឆ្លូវ ត្រីស័ក ព.ស២៥៦៥

បាត់ដំបង ថ្ងៃទី១៤ ខែមករា ឆ្នាំ២០២២

**ក្រឡាបញ្ជី**

[redacted]